# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងព័ត៌មាន

លេខ ១៨៧ ព.មសសរ

ថ្ងៃច័ន្ទ ៩រោច ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែសីហា ឆ្នាំ២០២១

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការតាមដាន វាយតម្លៃ និងលើកសរសើរ ការអនុវត្តក្រមសីលធម៌ វិជ្ជាជីវៈសារព័ត៌មាន

## រដ្ឋមន្ត្រីក្រសួងព័ត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៧ ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសារព័ត៌មាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងព័ត៌មាន
- បានឃើញអនុក្រឹត្យលេខ ៧១ អនក្រ.បក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋានរដ្ឋបាល និងសោតទស្សន៍ ជាអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ និងអគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងព័ត៌មាន

## សម្រេច

**ប្រការ១.**_

ត្រូវបានបង្កើតគណៈកម្មការតាមដាន វាយតម្លៃ និងលើកសរសើរ ចំពោះអ្នកសារព័ត៌មាន និងអង្គភាពសារព័ត៌មាន ដែលអនុវត្តបានត្រឹមត្រូវតាមក្រមសីលធម៌ វិជ្ជាជីវៈសារព័ត៌មាន និងដាក់វិន័យចំពោះអ្នកសារព័ត៌មាន និងអង្គភាពសារព័ត៌មាន ដែលបានប្រព្រឹត្តល្មើសក្រមសីលធម៌ វិជ្ជាជីវៈ ដើម្បីតម្រង់ទិសអ្នកសារព័ត៌មាន ក្នុងការបំពេញភារកិច្ចរបស់ខ្លួនឱ្យបានត្រឹមត្រូវតាមក្រមសីលធម៌ វិជ្ជាជីវៈ សំដៅលើកស្ទួយកិត្តិយស សេចក្តីថ្លៃថ្នូរ និងកិត្យានុភាពរបស់អ្នកសារព័ត៌មាន និងអង្គភាពសារព័ត៌មាន។

គណៈកម្មការនេះ មានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. ឯកឧត្តម ប៉ិត បូរ៉ុត | រដ្ឋលេខាធិការក្រសួងព័ត៌មាន | ប្រធាន |
| ២. ឯកឧត្តម តន់ យ៉ាន | រដ្ឋលេខាធិការក្រសួងព័ត៌មាន | អនុប្រធាន |
| ៣. ប្រធានសមាគមទូរទស្សន៍កម្ពុជា | | អនុប្រធាន |
| ៤. ឯកឧត្តម ផុស សុវណ្ណ | ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយកព័ត៌មាន និងសោតទស្សន៍ | អនុប្រធានអចិន្ត្រៃយ៍ |
| ៥. លោកជំទាវ ឌៃ ច័ន្ទវិទ្ធីសូលីដា | រដ្ឋលេខាធិការក្រសួងព័ត៌មាន | សមាជិក |
| ៦. ឯកឧត្តម មាស សុភ័ណ្ឌ | អនុរដ្ឋលេខាធិការក្រសួងព័ត៌មាន | សមាជិក |
| ៧. ឯកឧត្តម ឃួន វិចិត្រ | អនុរដ្ឋលេខាធិការក្រសួងព័ត៌មាន | សមាជិក |
| ៨. ឯកឧត្តម ម៉ែន សាម៉ន | អនុរដ្ឋលេខាធិការក្រសួងព័ត៌មាន | សមាជិក |
| ៩. ឯកឧត្តម មឿន ឈានណារិទ្ធ | ទីប្រឹក្សាក្រសួងព័ត៌មាន | សមាជិក |
| ១០. ប្រធានសមាគមវិទ្យុកម្ពុជា | | សមាជិក |
| ១១. ប្រធានសហភាពសហព័ន្ធអ្នកសារព័ត៌មានកម្ពុជា (សសសក) | | សមាជិក |
| ១២. ប្រធានក្លិបអ្នកកាសែតកម្ពុជា (ក.អ.ក) | | សមាជិក |
| ១៣. ប្រធានសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (ខេមបូចា) | | សមាជិក |
| ១៤. ប្រធានសមាគមអ្នកសារព័ត៌មានខ្មែរប្រជាធិបតេយ្យ | | សមាជិក |
| ១៥. ប្រធានសមាគមកម្ពុជាការពារអ្នកកាសែត | | សមាជិក |

**ខ. គណៈកម្មការនេះមានភារកិច្ចដូចខាងក្រោម៖**

- ដឹកនាំប្រជុំពិនិត្យតាមការកំណត់ និងការចាំបាច់ ពិនិត្យលើរបាយការណ៍ និងការតវ៉ាពីសារ-ធារណជន ឬ អង្គភាពស្ថាប័ននានា
- ដោះស្រាយបណ្តឹងតវ៉ា ដែលទាក់ទងនឹងក្រមសីលធម៌ វិជ្ជាជីវៈសារព័ត៌មានរវាងអ្នកសារព័ត៌មាន អង្គភាពសារព័ត៌មាន ជាមួយបុគ្គល ឬក្រសួង ស្ថាប័ន ឬអ្នកសារព័ត៌មាន អង្គភាពសារព័ត៌មាន
- ពិនិត្យ វាយតម្លៃការអនុវត្តរបស់អ្នកសារព័ត៌មាន អង្គភាពសារព័ត៌មាន ដើម្បីផ្តល់យោបល់ជូនថ្នាក់ដឹកនាំក្រសួងពិនិត្យ និងសម្រេច
- ស្នើសុំការសម្រេចពីថ្នាក់ដឹកនាំក្រសួង លើកទឹកចិត្ត លើកសរសើរអ្នកសារព័ត៌មាន និងអង្គភាពសារព័ត៌មាន ដែលមានស្នាដៃក្នុងការផ្តល់ព័ត៌មាន និងគោរពតាមក្រមសីលធម៌វិជ្ជាជីវៈ និងដាក់វិន័យអ្នកដែលប្រព្រឹត្តខុសពីក្រមសីលធម៌ វិជ្ជាជីវៈ តាមច្បាប់ស្តីពីរបបសារព័ត៌មាន
- អញ្ជើញអ្នកជំនាញសារព័ត៌មាន ឬម្ចាស់អង្គភាពសារព័ត៌មាន ឬប្រធានសមាគមអ្នកសារព័ត៌មាន ឬអង្គភាព ស្ថាប័នពាក់ព័ន្ធនានា មកពិគ្រោះយោបល់ក្នុងករណីចាំបាច់។

**ប្រការ២.** _

គណៈកម្មការនេះ មានរបៀបរបបដឹកនាំ និងសម្រេចការងារដូចខាងក្រោម៖

- រៀបចំកិច្ចប្រជុំក្នុងបូកសរុបលទ្ធផលការងារការកំណត់និងការចាំបាច់
- កិច្ចប្រជុំអាចដំណើរការទៅបានលុះត្រាតែសមាជិកមានចំនួន ពីរភាគបី នៃសមាជិកសរុបរបស់គណៈកម្មការ
- ការសម្រេចរបស់អង្គប្រជុំដែលអាចយកជាការបានលុះត្រាតែមានសំឡេងហាសិបភាគរយបូកមួយនៃសមាជិកអង្គប្រជុំ។

**ប្រការ៣.** _

អគ្គនាយកដ្ឋានព័ត៌មាននិងសោតទស្សន៍ ជាសេនាធិការឱ្យគណៈកម្មការសម្រាប់កិច្ចការដូចខាងក្រោម៖

- តាមដាន និងផ្តល់របាយការណ៍ស្តីពីការអនុវត្តរបស់អ្នកសារព័ត៌មាន ក្នុងការបំពេញវិជ្ជាជីវៈលើវិស័យព័ត៌មាននៅក្នុងព្រះរាជាណាចក្រកម្ពុជា
- រៀបចំសំណុំឯកសារជូនគណៈកម្មការ ដើម្បីពិនិត្យសម្រេច
- រៀបចំលិខិតអញ្ជើញ របៀបវារៈសម្រាប់កិច្ចប្រជុំ តាមការកំណត់របស់គណៈកម្មការ
- រៀបចំរបាយការណ៍នៃកិច្ចប្រជុំ របាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ជូនថ្នាក់ដឹកនាំក្រសួង
- បំពេញភារកិច្ចផ្សេងទៀតតាមការចាំបាច់ដែលថ្នាក់ដឹកនាំប្រគល់ជូន។

**ប្រការ៤.** _

នាយកខុទ្ទកាល័យក្រសួងព័ត៌មាន អគ្គនាយកនៃអគ្គនាយកដ្ឋានជំនាញចំណុះក្រសួងព័ត៌មាន មន្ទីរព័ត៌មានរាជធានី ខេត្ត និងសាមីខ្លួនដូចមានចែងនៅក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រី**

ក្រសួងព័ត៌មាន

**ខៀវ កាញារីទ្ធ**

**<u>ចម្លងជូន៖</u>**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- សមាគមអ្នកសារព័ត៌មាន - វិទ្យុ - ទូរទស្សន៍

"**ដើម្បីគោរពជូនជ្រាប**"

- ដូចប្រការ១ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ